ការផ្សាយរបស់សមាគមបណ្ដាញយុវជនកម្ពុជា

# សៀវភៅណែនាំស្ដីពី

# ក្រមសីលធម៌សម្រាប់

# អ្នកប្រើប្រាស់អ៊ីនធឺណិត

ការផលិត និងបោះពុម្ពផ្សាយសៀវភៅណែនាំស្តីពី ក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិត នេះត្រូវបានធ្វើឡើងក្រោមជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីអង្គការ American Jewish World Service (AJWS)។ ម្ចាស់មូលនិធិមិនបានចូលរួមផ្តល់យោបល់លើដំណើរការស្រាវជ្រាវនិងខ្លឹមសារនៃសៀវភៅនេះឡើយ។ សមាគមបណ្តាញយុវជនកម្ពុជានិងអ្នកនិពន្ធទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារនៅក្នុងសៀវភៅនេះ។

©២០១៧, សមាគមបណ្តាញយុវជនកម្ពុជា

ការបោះពុម្ពលើកទី១

ប្រសិនបើអ្នកមានសំណូមពរ ឬមតិយោបល់ទាក់ទងនឹងសៀវភៅណែនាំស្តីពី
ក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតនេះ,
សូមមេត្តាទាក់ទងសមាគមបណ្តាញយុវជនកម្ពុជា តាមអាសយដ្ឋាន៖
ផ្ទះលេខ ៤៣D ផ្លូវ៣៧១ ភូមិត្រពាំងឈូក សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
អ៊ីមែល៖ info@cyncambodia.org
ទូរស័ព្ទ៖ +៨៥៥ (0) ១៧ ៩៩០៦៨៩/ +៨៥៥ (0) ១៦ ៩៣០ ៥៨៨
វិបសាយថ៍៖ www.cyncambodia.org

## សៀវភៅណែនាំស្ដីពី

# ក្រមសីលធម៌សម្រាប់ អ្នកប្រើប្រាស់អ៊ីនធឺណិត

ស្រាវជ្រាវនិងចងក្រងដោយ ប៉ា ចន្ទរឿន

# អារម្ភកថា

សមាគមបណ្ដាញយុវជនកម្ពុជា (ប.យ.ក) គឺជាសមាគមយុវជនឯករាជ្យ និងប្រជាធិបតេយ្យ ដែលកំពុងតែធ្វើការលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់យុវជន, សិស្ស, និស្សិតកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សានានា និងយុវជនដែលរស់នៅតាមសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ ប.យ.ក បង្កើតឡើងក្នុងគោលបំណងពង្រឹងសិទ្ធិអំណាចយុវជនតាមរយៈការចងក្រងបណ្ដាញយុវជន ការអភិវឌ្ឍសមត្ថភាព និងការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងសកម្មភាពសង្គមកម្ពុជាដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ប្រជាធិបតេយ្យ យុត្តិធម៌សង្គម ការពារធនធានធម្មជាតិ និងបរិស្ថាន ព្រមទាំងជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

សមាគមបណ្ដាញយុវជនកម្ពុជាចង់ឃើញយុវជនកម្ពុជាមានសិទ្ធិអំណាច សេរីភាពពេញលេញ និងរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរក្នុងសង្គមប្រជាធិតេយ្យពិតប្រាកដ។ ប.យ.ក ពង្រឹងអំណាចយុវជនតាមរយៈ ការអភិវឌ្ឍសមត្ថភាព ការចងក្រងបណ្ដាញយុវជន និងការគាំទ្រការតស៊ូមតិរបស់យុវជនកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អ យុត្តិធម៌សង្គម ការគោរពសិទ្ធិមនុស្ស ការងារសមរម្យ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

ដោយបានមើលឃើញពីកង្វះខាតនៃការយល់ដឹងរបស់អ្នកប្រើប្រាស់អ៊ីនធឺណិតនាពេលបច្ចុប្បន្នជាពិសេសក្នុងចំណោមយុវជនកម្ពុជាអំពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើក្នុងការប្រើប្រាស់អ៊ីនធឺណិត សមាគមបណ្ដាញយុវជនកម្ពុជាបានសហការជាមួយអ្នកស្រាវជ្រាវឯករាជ្យ លោក ប៉ា ចន្ទរឿន ដើម្បីចងក្រងសៀវភៅណែនាំស្ដីពីក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតនេះឡើង។ សៀវភៅណែនាំស្ដីពី ក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិត នេះត្រូវបានបោះពុម្ពផ្សាយជាភាសាខ្មែរ។ កូនសៀវភៅនេះត្រូវបានចែកជូនដល់យុវជន និងអ្នកប្រើប្រាស់អ៊ីនធឺណិតទូទៅ។ លើសពីនេះទៅទៀត យើងក៏ធ្វើ ការផ្សព្វផ្សាយសៀវភៅនេះនៅលើវ៉ិបសាយថ៍របស់ ប.យ.ក ដែលអ្នកប្រើប្រាស់អ៊ីនធឺណិតអាចចូលទៅទាញយកសៀវភៅនេះដើម្បីយកមកសិក្សាឈ្វេងយល់បាន។

តាងនាមឱ្យសមាគមបណ្ដាញយុវជនកម្ពុជា (ប.យ.ក) ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងពន់ពេកក្នុងការបោះពុម្ពផ្សាយសៀវភៅណែនាំស្ដីពីក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតដែលជាសមិទ្ធផលថ្មីមួយទៀតរបស់ ប.យ.ក។ ខ្ញុំជឿជាក់ថា សៀវភៅដែលអ្នកកំពុងតែកាន់នៅក្នុងដៃនេះនឹងរួមចំណែកក្នុងការផ្ដល់នូវចំណេះដឹងដល់អ្នកអំពីក្រមសីលធម៌នៃការប្រើប្រាស់អ៊ីនធឺណិតព្រមទាំងជួយលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិ លើអ៊ីនធឺណិតនៅ

កម្ពុជាឱ្យកាន់តែប្រសើរ និងមានការទទួលខុសត្រូវខ្ពស់។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកសមាជិកា របស់ ប.យ.ក អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម បុគ្គលិកអង្គការសង្គមស៊ីវិល អ្នកសារព័ត៌មានអនឡាញ និងបុគ្គលិកក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត និស្សិត បញ្ញវន្តដែលបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងស្ទង់មតិនៅតាមអ៊ីនធឺណិតកន្លងមក ព្រមទាំងបានផ្តល់ជូនជាព័ត៌មាន និងអនុសាសន៍ផ្សេងៗស្តីពីស្ថានភាពសីលធម៌នៃអ្នកប្រើប្រាស់អ៊ីធឺណិតនៅកម្ពុជាសព្វថ្ងៃ។ ជាពិសេសសូមថ្លែងអំណរគុណ លោក ប៉ា ចន្ទរឿន អ្នកស្រាវជ្រាវប្រឹក្សាឯករាជ្យដែលបានខិតខំប្រឹងប្រែងចងក្រងសៀវភៅណែនាំស្តីពីក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតនេះប្រកបដោយជោគជ័យ។ ការចូលរួមកិច្ចសហការ និងការគាំទ្រដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នានឹងជួយលើកកម្ពស់តម្លៃសីលធម៌ និងការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយការទទួលខុសត្រូវនៅកម្ពុជា៕

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧

ប្រធានសមាគមបណ្តាញយុវជនកម្ពុជា

**ទឹម ម៉ាឡៃ**

# សារបណ្ណ

អារម្ភកថា ........................................................ 3
សារបណ្ណ ........................................................ 6
សេចក្តីផ្តើម........................................................ 7
វិធីសាស្ត្រស្រាវជ្រាវ............................................. 10
គោលការណ៍សំខាន់ៗទាំងប្រាំនៃក្រមសីលធម៌
សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិត........................ 12
គោលការណ៍ទី១៖
សុភនិច្ឆ័យក្នុងការប្រើប្រាស់អ៊ីនធឺណិត................. 13
គោលការណ៍ទី២៖
ការទទួលខុសត្រូវនិងការគិតពីសុវត្ថិភាពក្នុងការ
ប្រើប្រាស់អ៊ីនធឺណិត............... ..................... 15
គោលការណ៍ទី៣៖
ការប្រើប្រាស់ខ្លឹមសារត្រឹមត្រូវ.............................. 21
គោលការណ៍ទី៤៖
ការគោរពនិងការពារទ្រព្យសម្បត្តិ....................... 28
គោលការណ៍ទី៥៖
ការគោរពជីវភាពឯកជន................................. 30

# សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ ២០១០ មក វិស័យសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT) នៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមគ្នានោះដែរចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជាក៏បានកើនឡើងយ៉ាងច្រើន។ យោងតាមស្ថិតិពីក្រសួងប្រៃសណីយ៍និងទូរគមនាគន៍កម្ពុជា បានបង្ហាញថា នៅឆ្នាំ២០១០ ប្រជាពលរដ្ឋខ្មែរប្រមាណជាង ៣២០.០០០ នាក់ បានប្រើប្រាស់អ៊ីនធឺណិត។ ហើយនៅចុងឆ្នាំ២០១៣ ចំនួននេះបានកើនឡើងជាង ១០ដង គឺរហូតដល់ ៣,៨ លាននាក់ ដែលស្មើរតែស្មើនឹងមួយភាគបួននៃចំនួន ប្រជាជនកម្ពុជាសរុប។[1] នៅដើមខែកុម្ភៈ ឆ្នាំ២០១៧, ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតសកម្មនៅកម្ពុជាបានកើនរហូតដល់ ៧,១ លាននាក់នៃចំនួនប្រជាជន សរុប ១៥,៩លាន នាក់។[2]

ប្រព័ន្ធផ្សព្វផ្សាយសង្គម (social media) កំពុងទទួលការពេញនិយមយ៉ាងខ្លាំងក្នុងចំណោមអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា ជាពិសេសហ្វេសប៊ុក (Facebook) បានក្លាយជាដែនឌីជីថលដ៏សំខាន់សម្រាប់អ្នកប្រើប្រាស់កម្ពុជាភាគច្រើន។ នៅខែ មីនា ឆ្នាំ២០១៧

[1] របាយការណ៍របស់អង្គការលីការដូស្តីពី ដំណើរឃ្លាតចេញពីអ៊ីនធឺណិត, ចេញផ្សាយខែឧសភា ឆ្នាំ២០១៥

[2] ដកស្រង់ចេញពីគេហទំព័រ http://geeksincambodia.com (ដកស្រង់ព័ត៌មានចុងក្រោយ នៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៧)

ប្រជាជនកម្ពុជាដែលបានប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុកមានចំនួន ៤,៩ លាននាក់ ហើយអ្នកប្រើប្រាស់ជាង ៧0% មានអាយុចន្លោះពី ១៨ ដល់ ៣៤ឆ្នាំ។[3]

យោងតាមការសង្កេតជាទូទៅ សកម្មភាពរបស់អ្នកប្រើប្រាស់ហ្វេសប៊ុកនៅកម្ពុជា ភាគច្រើនហាក់បីដូចជាខ្វះការយល់ដឹងអំពីក្រមសីលធម៌នៃការប្រើប្រាស់អ៊ីនធឺណិត។ សកម្មភាពបែបនោះបានធ្វើឱ្យពួកគេកំពុងប្រឈមនឹងផលវិបាកទាំងផ្នែកសីលធម៌ និងផ្លូវច្បាប់ ដោយសារតែអ្វីៗ ដែលពួកគេបង្ហោះនិងចែករំលែកនៅលើហ្វេសប៊ុក។ ឧទាហរណ៍អ្នកប្រើប្រាស់ ហ្វេសប៊ុកខ្លះដែលប្រើប្រាស់ពាក្យអសុរោះ ត្រូវបានអ្នកប្រើប្រាស់ហ្វេសប៊ុកដទៃទៀតរិះគន់ចំពោះទង្វើរបស់គេ។ មានករណីខ្លះ អ្នកប្រើប្រាស់ហ្វេសប៊ុកមួយចំនួនបានសម្តែងអាកប្បកិរិយា អសីលធម៌ចំពោះមេដឹកនាំក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបញ្ជូនទៅតុលាការ និងត្រូវរងការផ្តន្ទាទោសឱ្យជាប់គុកទៀតផង។

ដោយបានមើលឃើញបញ្ហាទាំងនេះសមាគមបណ្តាញយុវជនកម្ពុជា (CYN) បានផ្តួចផ្តើមគម្រោងចងក្រងសៀវភៅណែនាំស្តីពីក្រមសីលធម៌[4] សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិត នេះឡើង។ សមាគម

---

[3] *ប្រភព We Are Social (ដកស្រង់ព័ត៌មានចុងក្រោយ នៅខែមីនា ឆ្នាំ២០១៧)*

[4] ***ក្រមសីលធម៌*** *គឺជាគោលការណ៍ណែនាំបុគ្គល ជាពិសេសមនុស្សដែលមានវិជ្ជាជីវៈនូវអ្វីដែលគួរធ្វើនិងមិនគួរធ្វើ។* ***សីលធម៌អ៊ីនធឺណិត*** *សំដៅលើអាកប្បកិរិយាដែលអាចទទួលយកបានរបស់អ្នកប្រើប្រាស់អ៊ីនធឺណិត។ ជាគោលការណ៍, អ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវមានសេចក្តីទៀងត្រង់, គោរពឯកជនភាពនិងទ្រព្យសម្បត្តិរបស់អ្នកដទៃនៅលើអ៊ីនធឺណិត។ ក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវបានបែងចែកជា៥ គោលការណ៍សំខាន់៖*

បណ្ដាញយុវជនកម្ពុជា ព្រមទាំងអ្នកស្រាវជ្រាវចងក្រងសៀវភៅនេះ សង្ឃឹមថាសៀវភៅណែនាំនេះនឹង៖

- ក្លាយជាឯកសារពិគ្រោះសម្រាប់បង្កើនការយល់ដឹងរបស់អ្នកប្រើប្រាស់អ៊ីនធឺណិត អំពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើនៅពេលប្រើប្រាស់អ៊ីនធឺណិត។
- លើកកម្ពស់សិទ្ធិនិងសេរីភាពនៃការបញ្ចេញមតិប្រកបដោយការគោរព និងការទទួលខុសត្រូវ ជាពិសេសក្នុងចំណោមអ្នកប្រើប្រាស់អ៊ីនធឺណិត និង
- កាត់បន្ថយការប្រឈម សកម្មភាពអសីលធម៌ និងការប្រព្រឹត្តខុសច្បាប់ក្នុងចំណោមអ្នកប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជា។

---

*(១) សុភនិច្ឆ័យក្នុងការប្រើប្រាស់អ៊ីនធឺណិត, (២) ការប្រើប្រាស់ខ្លឹមសារត្រឹមត្រូវ, (៣) ការទទួលខុសត្រូវនិងសុវត្ថិភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត, (៤) ការគោរពនិងការពារទ្រព្យសម្បត្តិ, (៥) ការគោរពជីវភាពឯកជន។*

# វិធីសាស្ត្រស្រាវជ្រាវ

ទិន្នន័យសម្រាប់ការចងក្រងសៀវភៅណែនាំស្តីអំពីក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតនេះបានមកពី៖

- ឯកសារយោងទាក់ទងនឹងបញ្ហាសីលធម៌ និងការប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជាសព្វថ្ងៃ និងក្រមសីលធម៌សម្រាប់អ្នកសារ-ព័ត៌មាន។

- ទិន្នន័យដែលបានមកពីសិក្ខាសាលាប្រឹក្សាយោបល់អំពីស្ថានភាពសីលធម៌នៃការប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជានាពេលបច្ចុប្បន្នចំនួនពីរលើកជាមួយនឹងអ្នកជំនាញខាងអ៊ីនធឺណិត អ្នកសារព័ត៌មាន មន្ត្រីអង្គការសង្គមស៊ីវិល អ្នកអប់រំ សិស្ស-និស្សិត និងភាគីដែលពាក់ព័ន្ធដទៃទៀត។

- ទិន្នន័យបានមកពីការស្ទង់មតិដែលបានធ្វើតាមអ៊ីនធឺណិតក្នុងរយៈពេលមួយខែស្តីពីស្ថានភាពសីលធម៌នៃការប្រើប្រាស់អ៊ីនធឺណិតនៅកម្ពុជានាពេលបច្ចុប្បន្ន។

ដំបូងសេចក្តីព្រាងសៀវភៅត្រូវបានចងក្រងឡើងដោយយកទិន្នន័យដែលប្រមូលបានពីការស្រាវជ្រាវមកសិក្សា វិភាគនិងចងក្រង

ចេញជាគោលគំនិតស្តីពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើក្នុងការប្រើប្រាស់អ៊ីនធឺណិត។

បន្ទាប់មកសេចក្តីព្រាងសៀវភៅនេះត្រូវបានយកទៅសិក្សាពិភាក្សា និងត្រួតពិនិត្យនៅក្នុងសិក្ខាសាលាប្រឹក្សាយោបល់លើកទីបីជាមួយនឹងភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងការប្រឹក្សាយោបល់និងការស្ទង់មតិពីមុន។ គោលបំណងនៃសិក្ខាសាលាប្រឹក្សាយោបល់ទីបីនេះគឺដើម្បីសុំមតិត្រឡប់មកវិញទាក់ទងនឹងមាតិកានិងខ្លឹមសារនៃសៀវភៅទាំងមូល។

ជាទីបញ្ចប់សេចក្តីព្រាងសៀវភៅក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតត្រូវបានត្រួតពិនិត្យនិងកែតម្រូវឡើងវិញតាមការផ្តល់យោបល់នៅក្នុងសិក្ខាសាលាប្រឹក្សាយោបល់ទីបីមុននឹងវាត្រូវបានបោះពុម្ពនិងផ្សព្វផ្សាយជាសាធារណៈ។

សៀវភៅណែនាំស្តីពីក្រមសីលធម៌សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតនេះត្រូវបានចងក្រងឡើងក្នុងទម្រង់សាមញ្ញ ជាអ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើក្នុងការប្រើប្រាស់អ៊ីនធឺណិតដើម្បីបង្កភាពងាយស្រួលយល់ដល់អ្នកអានគ្រប់កម្រិត។

# គោលការណ៍សំខាន់ៗទាំងប្រាំនៃ
# ក្រមសីលធម៌សម្រាប់
# អ្នកប្រើប្រាស់អ៊ីនធឺណិត

## គោលការណ៍ទី ១

# សុតនិច្ឆ័យក្នុងការប្រើប្រាស់អ៊ីនធឺណិត

គោលការណ៍ទី១នេះសំដៅលើគោលការណ៍ណែនាំជាទូទៅ ដែលអ្នកប្រើប្រាស់អ៊ីនធឺណិតគួរយល់ដឹងនិងប្រតិបត្តិ។

- អ៊ីនធឺណិតនាំមនុស្សឱ្យស្គាល់គ្នាទោះបីជាពួកគេខ្លះមិនធ្លាប់ជួបមុខគ្នាដោយផ្ទាល់ក៏ដោយ ហេតុនេះចូរអ្នកចងចាំថាអ្នកទាក់ទងជាមួយនឹងមនុស្សដូចគ្នានៅតាមអ៊ីនធឺណិត។

- ប្រសិនបើអ្នកទើបតែចាប់ផ្តើមប្រើប្រាស់អ៊ីនធឺណិតដំបូង អ្នកគួរតែសិក្សាពីវាដើម្បីឱ្យមានការយល់ដឹងពីអ៊ីនធឺណិតឱ្យបានទូលំទូលាយ ជាពិសេសឈ្វេងយល់ពីគុណសម្បត្តិ និងផលវិបាកនៃការប្រើប្រាស់អ៊ីនធឺណិត (សម្រាប់ព័ត៌មានបន្ថែមសូមអានសៀវភៅណែនាំអំពីបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍របស់ក្រសួងអប់រំយុវជននិងកីឡា។

- ត្រូវឈ្វេងយល់ពីសិទ្ធិ សេរីភាព និងការទទួលខុសត្រូវរបស់អ្នកក្នុងការប្រើប្រាស់អ៊ីនធឺណិត ទទួលនិងផ្សព្វផ្សាយព័ត៌មាន។

- មុននឹងផ្ញើ ផ្សព្វផ្សាយ និងចែករំលែកអ្វីមួយបន្តនៅលើ

បណ្ដាញអ៊ីនធឺណិត អ្នកគួរតែសួរខ្លួនឯងនូវសំណួរខាងក្រោមនេះជាមុនៈ តើវាពិតទេ? តើវាមានប្រយោជន៍ទេ? តើវាចាំបាច់ទេ? តើវាជំរុញចិត្តទេ (Is it inspired)? តើវាសប្បុរសទេ (Is it kind)?

• ផ្ញើ ផ្សព្វផ្សាយ និងចែករំលែកអ្វីដែលមានខ្លឹមសារជាលក្ខណៈអប់រំ កម្សាន្ត និងជាព័ត៌មានដើម្បីលើកកម្ពស់ការយល់ដឹង សេរីភាពនៃការបញ្ចេញមតិ បង្កើនជំនាញ ការច្នៃប្រឌិតនិងការផ្លាស់ប្ដូរឥរិយាបថបែបវិជ្ជមានសម្រាប់សង្គម។

• ត្រូវប្រកាន់យកផ្នត់គំនិតជជែកពិភាក្សាគ្នាតាមអ៊ីនធឺណិតដើម្បីយល់ដឹងនិងរៀនសូត្រពីគ្នាទៅវិញទៅមកជាជាងដើម្បីយកចាញ់ឈ្នះជាមួយអ្នកដទៃ។

• មិនគួរធ្វើដាក់អ្នកដទៃនូវទង្វើទាំងឡាយណាដែលអ្នកមិនចង់ឱ្យអ្នកដទៃធ្វើមកលើអ្នកនៅលើប្រព័ន្ធអ៊ីនធឺណិត។

## គោលការណ៍ទី ២

# ការទទួលខុសត្រូវ និងការគិតពីសុវត្ថិភាព ក្នុងការប្រើប្រាស់អ៊ីនធឺណិត

អ្នកប្រើប្រាស់អ៊ីនធឺណិតគួរយកចិត្តទុកដាក់ចំពោះសុវត្ថិភាពរបស់ខ្លួននិងអ្នកប្រើប្រាស់ដទៃនៅពេលប្រើប្រាស់ អ៊ីនធឺណិតពីព្រោះសុវត្ថិភាពនៅលើអ៊ីនធឺណិតក៏សំខាន់ដូចសុវត្ថិភាពនៅក្នុងសង្គមជាក់ស្តែងដែរ។

### ត្រូវធ្វើ

• ត្រូវឈ្វេងយល់ពីសុវត្ថិភាពនិងវិធីរក្សាសុវត្ថិភាពខ្លួនអ្នកនិងឧបករណ៍អេឡិចត្រូនិចរបស់អ្នកនៅពេលដែលអ្នកប្រើប្រាស់អ៊ីនធឺណិត។ ឧទាហរណ៍៖ មិនគួរបង្ហាញទីតាំងដែលខ្លួនកំពុងស្ថិតនៅតាម*អ៊ីនធឺណិត*។

• ត្រូវកំណត់លក្ខខណ្ឌសុវត្ថិភាពគណនី ឬអ៊ីមែលរបស់ខ្លួនឱ្យបានត្រឹមត្រូវ។ ឧទាហរណ៍៖ *ការប្រើប្រាស់ពាក្យសម្ងាត់ដែលអ្នកដទៃមិនងាយទាយត្រូវ និងរក្សាទុកវាឱ្យបានត្រឹមត្រូវ...* ។

• ត្រូវបិទបាំងពាក្យសម្ងាត់របស់អ្នកពេលដែលអ្នកកំពុងវាយវាបញ្ចូល (Log in)។

• ត្រូវដាក់ពាក្យសម្ងាត់ (passwords) ដែលគេមិនងាយស្មានត្រូវសម្រាប់ចាក់សោរ ឬបើកដំណើរការកុំព្យូទ័រ ទូរស័ព្ទដៃ ឬឧបករណ៍អេឡិចត្រូនិចរបស់អ្នកដើម្បីការពារកុំឱ្យអ្នកដទៃលួចប្រើប្រាស់ ឬដើម្បីរក្សាសុវត្ថិភាពទិន្នន័យនៅក្នុងឧបករណ៍ទាំងនោះក្នុងករណីវាត្រូវបាត់បង់។ ឧទាហរណ៍៖ *កុំដាក់ពាក្យសម្ងាត់ដែលជាថ្ងៃខែឆ្នាំកំណើតរបស់អ្នក ឬពាក្យសម្ងាត់ ១ ២ ៣ ៤...។ គួរជ្រើសរើសយកពាក្យសម្ងាត់ដែលមានប្រាំបីខ្ទង់យ៉ាងតិច ដោយមានលេខ អក្សរ អក្សរធំ (CAPITAL LETTERS) និងសញ្ញានៅក្នុងនោះ។*

• ត្រូវបិទឬចាក់សោរកុំព្យូទ័រ ទូរស័ព្ទដៃ ឬ ឧបករណ៍ អេឡិចត្រូនិចដទៃទៀតរបស់អ្នកនៅពេលដែលអ្នកចាកចេញពីកន្លែងធ្វើការ ឬមិននៅជាមួយឧបករណ៍ទាំងនោះ។

• ត្រូវផ្លាស់ប្តូរពាក្យសម្ងាត់គណនី ឬអ៊ីមែលរបស់អ្នកជាបន្ទាន់ បើអ្នកសង្ស័យថាវាត្រូវបានគេប៉ុនប៉ងលួចកាន់កាប់ ឬលួចចូលប្រើប្រាស់។

• ត្រូវប្រើប្រាស់កម្មវិធីកំចាត់មេរោគដែលមានប្រសិទ្ធិភាពដើម្បីរក្សាសន្តិសុខឧបករណ៍អេឡិចត្រូនិចរបស់អ្នក។

• ឪពុកម្ដាយ ឬអាណាព្យាបាលត្រូវយកចិត្តទុកដាក់អំពីសុវត្ថិភាពកូនចៅរបស់ខ្លួន ជាពិសេសអនីតិជនក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។

• ត្រូវយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នចំពោះសកម្មភាពបោកប្រាស់តាមអ៊ីនធឺណិតដែលជាប្រភេទបទល្មើសមួយដែលមានលក្ខណៈស្មុកស្មាញ និងត្រូវឈ្វេងយល់ពីវិធីការពារខ្លួនពីការឆបោក។

• ប្រើប្រាស់ឈ្មោះពិត និងគណនីពិតក្នុងការប្រើប្រាស់អ៊ីនធឺណិត ហើយត្រូវប្រុងប្រយ័ត្នចំពោះអ្នកប្រើប្រាស់ឈ្មោះក្លែងក្លាយតាមអ៊ីនធឺណិត។

• ត្រូវឈ្វេងយល់ពីព្រំដែននៃសិទ្ធិ សេរីភាព និងការទទួលខុសត្រូវរបស់អ្នកក្នុងការប្រើប្រាស់អ៊ីនធឺណិត។

• ត្រូវបិទ (Sign out) គណនី និងអ៊ីមែលរបស់អ្នកក្រោយពេលអ្នកឈប់ប្រើឧបករណ៍អេឡិចត្រូនិច ឬកុំព្យូទ័រសាធារណៈ។

• ត្រូវលប់ ឬបំផ្លាញចោលនូវរាល់ទិន្នន័យដែលអ្នកលែងត្រូវការប្រើប្រាស់។

• ត្រូវមានការប្រុងប្រយ័ត្នមុននឹងទទួលមិត្តភក្តិថ្មីម្នាក់ (new friend request) តាមបណ្ដាញសង្គមដូចជាហ្វេសប៊ុក ជាពិសេស

មនុស្សដែលអ្នកមិនធ្លាប់ស្គាល់ប្រវត្តិ។

• ត្រូវរាយការណ៍ទៅអ្នកគ្រប់គ្រង អាណាព្យាបាលរបស់អ្នក ឬសមត្ថកិច្ចដែលពាក់ព័ន្ធអំពីអ្វីដែលអ្នកបានជួបប្រទះនៅលើបណ្ដាញអ៊ីនធឺណិត ដែលគិតថាវាអាចបង្កអសន្តិសុខដល់ខ្លួនអ្នក អ្នកដទៃ និង/ឬសង្គមជាតិ។

• ត្រូវប្រឹក្សាយោបល់ជាមួយអ្នកជំនាញខាងអ៊ីនធឺណិត និងបច្ចេក វិទ្យាព័ត៌មាន និងសារគមនាគមន៍បើអ្នកមានចម្ងល់ទាក់ទងនឹងសុវត្ថិភាពនិងសន្តិសុខរបស់អ្នកក្នុងការប្រើប្រាស់អ៊ីនធឺណិត។

## មិនត្រូវធ្វើ

• មិនត្រូវអនុញ្ញាតិឱ្យអ្នកដទៃប្រើប្រាស់គណនី អ៊ីមែល ឬដឹងពាក្យសម្ងាត់របស់អ្នកព្រោះគេអាចយកវាទៅប្រើប្រាស់ក្នុងផ្លូវអវិជ្ជមានដែលអាចនាំបញ្ហាដល់អ្នក។

• មិនត្រូវប្រើប្រាស់ពាក្យសម្ងាត់តែមួយដូចគ្នាសម្រាប់គណនី ឬអ៊ីមែលរបស់អ្នកទាំងអស់។

• មិនត្រូវកត់ពាក្យសម្ងាត់នៅលើក្រដាស ឬឯកសារដែលអ្នកដទៃឱ្យរកបាន។

• មិនត្រូវបើកអ៊ីមែល ទាញយកឯកសារភ្ជាប់ ឬចុចលើតំណ

ភ្ជាប់អ៊ីនធឺណិតដែលអ្នកមិនស្គាល់ច្បាស់ ឬដែលគួរឱ្យសង្ស័យព្រោះគេអាចលួច (hack) គណនី និងបញ្ចូលមេរោគទៅក្នុងឧបករណ៍អេឡិចត្រូនិចរបស់អ្នកបាន។

• មិនត្រូវបើកគណនី អ៊ីមែល ឬឧបករណ៍អេឡិចត្រូនិចរបស់លោកអ្នកចោលពេលអ្នកមិននៅកន្លែងធ្វើការឬនៅទីសាធារណៈ។

• មិនត្រូវទាញយក ឬ បញ្ចូលកម្មវិធីណាដែលអ្នកមិនស្គាល់ប្រភពច្បាស់លាស់ដាក់ក្នុងឧបករណ៍អេឡិចត្រូនិចរបស់អ្នកឡើយ ព្រោះឧបករណ៍អេឡិចត្រូនិចរបស់អ្នកអាចឆ្លង មេរោគ ឬអាចប្រឈមមុខនឹងការលួចទិន្នន័យឬប្រើប្រាស់។

• មិនត្រូវជ្រៀតជ្រែកអ្នកប្រើប្រាស់អ៊ីនធឺណិតដទៃព្រោះវាជាការបំពានទៅលើអ្នកដទៃ។

• មិនត្រូវប្រើប្រាស់អ៊ីនធឺណិតដើម្បីបង្កភាពអសន្តិសុខដល់អ្នកប្រើប្រាស់អ៊ីនធឺណិតដទៃ សង្គមជាតិ និងពិភពលោក។ ឧទាហរណ៍៖ *ការប្រើប្រាស់អ៊ីនធឺណិតក្នុងគោលបំណង ធ្វើភេរវកម្មដែលបង្កឱ្យមានភាពអសន្តិសុខនៅក្នុងសង្គម និងក្នុងតំបន់ជាដើម។*

• មិនត្រូវបង្ហាញជាសាធារណៈនូវព័ត៌មានផ្ទាល់ខ្លួនដូចជាលេខលិខិតឆ្លងដែន ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន លេខទូរស័ព្ទ លេខអត្តសញ្ញាណប័ណ្ណ ស្លាកលេខយានជំនិះ លេខគណនីធនាគារទីតាំង

ដែលអ្នកកំពុងស្ថិតនៅ  កាតធនាគារនៅលើអ៊ីនធឺណិត  ឬហ្វេសប៊ុក ពីព្រោះគេអាចប្រើប្រាស់ព័ត៌មានទាំងនោះទៅធ្វើសកម្មភាពដែលអាចនាំឱ្យអ្នកមានគ្រោះថ្នាក់និងខូចប្រយោជន៍។

- មិនត្រូវទុកចិត្តឬជឿពាក្យលួងលោមរបស់បុគ្គលដែលអ្នកបានស្គាល់តាមអ៊ីនធឺណិតព្រោះអ្នកអាចក្លាយជាជនរងគ្រោះដោយការឆបោក  ការចាប់ជំរិត ឬឃាតកម្ម។

## គោលការណ៍ទី ៣

# ការប្រើប្រាស់ខ្លឹមសារត្រឹមត្រូវ

### ត្រូវធ្វើ

• ត្រូវធ្វើ ដាក់ផ្សាយនិងចែករំលែកព័ត៌មានប្រកបដោយការទទួលខុសត្រូវ។

• ត្រូវប្រើប្រាស់ភាសាថ្លៃថ្នូរនៅលើអ៊ីនធឺណិត។ អ្នកត្រូវគិតពីផលប៉ះពាល់នៃពាក្យពេចន៍ដែលអ្នកប្រើប្រាស់ក្នុងទំនាក់ទំនងតាមអ៊ីនធឺណិត។ អ្នកត្រូវសួរខ្លួនឯងថា៖ “តើអ្នកនឹងប្រើប្រាស់ពាក្យពេចន៍បែបនេះឬទេនៅពេលដែលអ្នកប្រាស្រ័យជាមួយនរណាម្នាក់ដោយផ្ទាល់? តើអ្នកចង់ឱ្យអ្នកដទៃប្រើប្រាស់ភាសាបែបនេះចំពោះអ្នកឬទេ? តើអ្នកចង់ឱ្យឪពុកម្តាយ ឬកូនចៅរបស់អ្នកឮ ឬ យកភាសាបែបនេះទៅប្រើប្រាស់បន្តឬទេ?” បើអ្នកឆ្លើយថា “**ទេ**” ចំពោះសំណួរទាំងនេះ ចូរកុំប្រើប្រាស់ភាសាបែបនេះ។

• ត្រូវផ្សព្វផ្សាយព័ត៌មានដែលមានមូលដ្ឋាន ឬប្រភពច្បាស់លាស់ និងត្រឹមត្រូវ ដូចជាព័ត៌មានផ្សព្វផ្សាយដោយស្ថាប័ន ឬភ្នាក់ងារ ដែលត្រូវបានទទួលស្គាល់ជាសាធារណៈ ឬព័ត៌មានដូចគ្នា

ដែលអ្នកទទួលបានពីប្រភពផ្សេងៗគ្នា។

• ត្រូវបញ្ចេញយោបល់ ឬ រិះគន់បែបស្ថាបនា មានន័យថាលើកយកបញ្ហាឬចំណុចអវិជ្ជមាននៃអ្វីមួយមកបង្ហាញនិងផ្តល់អនុសាសន៍ដំណោះស្រាយ។

• ត្រូវបិទបាំងមុខកេរខ្មាស ឬអត្តសញ្ញាណរបស់បុគ្គលឬជនរងគ្រោះនៅពេលអ្នកដាក់ផ្សាយរូបថត ឬវីដេអូរបស់គេនៅលើបណ្តាញសង្គមពីព្រោះរូបភាពនិងអត្តសញ្ញាណខ្លះអាចនាំឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គលនោះ ឬក្រុមគ្រួសាររបស់ពួកគេ ឬសុខុមាលភាពសាធារណៈ។

• ត្រូវផ្ទៀងផ្ទាត់ព័ត៌មាន ឬសារមុនពេលដាក់ផ្សាយឬចែករំលែកបន្តពីព្រោះសារដែលមានកំហុសនឹងបង្កបញ្ហាដល់ខ្លួនអ្នកនិង/ឬអ្នកដទៃ។

• ត្រូវបញ្ជាក់ពីស្នាដៃឬប្រភពព័ត៌មានដើម សារ រូបថត ឬវីដេអូដែលអ្នកយកមកប្រើប្រាស់ ផ្សព្វផ្សាយ ឬចែករំលែកបន្ត។

• ត្រូវមានការប្រុងប្រយ័ត្ននៅពេលអ្នកផ្ញើ ដាក់ផ្សាយរូបថត ឬវីដេអូ ដោយអ្នកត្រូវគិតពីខ្លឹមសាររបស់រូបថត និង វីដេអូទាំងនោះក៏ដូចជាផលវិបាកដែលខ្លួនអ្នកនិងអ្នកដទៃនឹងទទួលរងដោយសារវាពីព្រោះថានៅពេលដែលវានៅលើអ៊ីនធឺណិត វានឹងនៅទីនោះរហូត

ហើយមនុស្សរាប់លាននាក់អាចថតវាទុក និងផ្សព្វផ្សាយបន្តទៅទៀត។ អ្នកត្រូវសួរខ្លួនឯងថា៖ “ប្រសិនបើអ្នកជារូបគេវិញ តើអ្នកចង់ឱ្យគេផ្សព្វផ្សាយព័ត៌មាននោះតាមអ៊ីនធឺណិតឬទេ? តើវាជារូបថត ឬវីដេអូដែលអ្នកចង់ឱ្យឪពុកម្ដាយឬកូនចៅរបស់អ្នកឃើញឬទេ? តើអ្នកចង់ឱ្យចៅហ្វាយ និយោជក ឬនិយោជកនាពេលអនាគតរបស់អ្នកឃើញវាឬទេ?”

• ត្រូវយោគយល់ និងអធ្យាស្រ័យដល់អ្នកប្រើប្រាស់អ៊ីនធឺណិតដទៃទៀតនៅពេលផ្តល់មតិ ឬពិភាក្សាតាមអ៊ីនធឺណិត។

• ត្រូវគោរពសិទ្ធិកុមារ និងស្ត្រីដោយមិនដាក់ផ្សាយឬចែករំលែកបន្តនូវរូបភាព វីដេអូ ខ្សែអាត់សំឡេង ឬអត្ថបទដែលប៉ះពាល់ដល់ឯកជនភាព គុណតម្លៃ និងសេចក្តីថ្លៃថ្នូររបស់កុមារនិងស្ត្រី។

## មិនត្រូវធ្វើ

• មិនត្រូវប្រើប្រាស់ពាក្យពេចន៍អសុរោះ ដូចជាការជេរប្រមាថជាដើម ពីព្រោះការប្រើប្រាស់ភាសាបែបនេះមិនត្រឹមតែប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់តម្លៃរបស់សង្គមជាតិផងដែរ។ អ្នកដែលប្រើប្រាស់ពាក្យពេចន៍អសុរោះនៅតាមអ៊ីនធឺណិតអាចប្រឈមមុខនឹងវិបាកផ្នែកសីលធម៌ ហើយ ពួកគេក៏

អាចប្រឈមមុខនឹងបណ្តឹងបរិហារកេរ្តិ៍តាមផ្លូវច្បាប់ផងដែរ។

• មិនត្រូវប្រើពាក្យព្រុះព្រង់ ឬអុជអាលដែលនាំឱ្យប៉ះពាល់ដល់ប្រពៃណីទំនៀមទម្លាប់ សណ្តាប់ធ្នាប់ សុខុមាលភាព សុវត្ថិភាពនិងសន្តិសុខជាតិព្រោះអ្នកអាចប្រឈមមុខនឹងបណ្តឹងព្រហ្មទណ្ឌតាមផ្លូវច្បាប់។

• មិនត្រូវប្រើប្រាស់អ៊ីនធឺណិតជាវេទិកាដើម្បីផ្សព្វផ្សាយព័ត៌មានណាដែលនាំឱ្យប៉ះពាល់កេរ្តិ៍ឈ្មោះឬ បរិហាកេរ្តិ៍អ្នកដទៃពីព្រោះមនុស្សម្នាក់ៗតែងតែស្រលាញ់កេរ្តិ៍ឈ្មោះរបស់ខ្លួន។

• មិនត្រូវប្រើប្រាស់អ៊ីនធឺណិតដើម្បីលាបពណ៌ ឬចោទប្រកាន់នរណាម្នាក់ដោយគ្មានហេតុផល ឬគ្មានភ័ស្តុតាងត្រឹមត្រូវនិងគ្រប់គ្រាន់ឡើយ។

• មិនត្រូវផ្សព្វផ្សាយរូបភាព វីដេអូ និងសារជាសំឡេងកាត់តមិនពិតពីព្រោះវាប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ហើយអ្នកក៏អាចប្រឈមមុខចំពោះបណ្តឹងតាមផ្លូវច្បាប់ផងដែរ។

• មិនត្រូវយករូបភាព វីដេអូ សារអក្សរ និងសារជាសំឡេងដែលមានលក្ខណៈ ឯកជនមកផ្សព្វផ្សាយជាសាធារណៈដោយមិនមានការយល់ព្រមពីសាម៉ីជនពីព្រោះវាប៉ះពាល់ដល់ជីវភាពឯកជន (Privacy) របស់គេ។

• មិនត្រូវផ្ញើ ផ្សព្វផ្សាយ ឬចែករំលែកសារ រូបភាព ឬវីដេអូដែលមានលក្ខណៈគំរាម ការជំរិត សម្លុតធ្វើបាបអ្នកដទៃពីព្រោះវាជាទង្វើអសីលធម៌ ហើយវាក៏អាចឈានដល់ទង្វើល្មើសច្បាប់ដែលអ្នកប្រព្រឹត្តអាចប្រឈមមុខនឹងការប្ដឹង ផ្ដល់តាមតុលាការ។

• មិនត្រូវផ្សព្វផ្សាយ ឬចែករំលែករូបភាពឬវីដេអូជនរងគ្រោះដែលមានសភាពគួរឱ្យរន្ធត់និងតក់ស្លុត ដូចជានៅក្នុងព្រឹត្តិការណ៍ឃាតកម្ម ឬគ្រោះថ្នាក់ចរាចរណ៍ណាមួយដោយមិនបានបិទបាំងកេរខ្មាស ឬអត្តសញ្ញាណពីព្រោះវានាំឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់សាមីជននិងសុខភាពផ្លូវចិត្តរបស់អ្នកទស្សនា។

• មិនត្រូវផ្សព្វផ្សាយព័ត៌មានណាមួយដែលអាចធ្វើឱ្យសាធារណជន ភាន់ច្រឡំ មានកំហឹង ឬ ភ័យខ្លាច។

• មិនត្រូវផ្សព្វផ្សាយរូបភាព និងវីដេអូអាសអាភាសព្រោះវាធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរនិងវប្បធម៌របស់ជាតិ។

• មិនត្រូវចែករំលែកព័ត៌មានដែលគ្មានប្រភពច្បាស់លាស់ ខ្វះសីលធម៌ ខ្វះការពិតដែលនាំឱ្យមានការស្អប់ខ្ពើមជាតិសាសន៍ អ្នកកាន់សាសនាណាមួយ និងបុគ្គលមានឋានៈណាមួយនៅក្នុងសង្គមជាដើម។

• មិនត្រូវប្រកាន់ឥរិយាបថជ្រុលនិយមក្នុងការជជែក ឬពិភាក្សាតាមបណ្តាញសង្គមពីព្រោះទស្សនៈជ្រុលនិយមអាចបង្កឱ្យមានជម្លោះ។

• មិនត្រូវផ្សព្វផ្សាយព័ត៌មានដែលជំរុញឱ្យប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង លេងល្បែងស៊ីសង និងប្រព្រឹត្តអំពើហិង្សាជាដើម។

• មិនត្រូវបង្ហាញអារម្មណ៍ ឬជីវិតផ្ទាល់ខ្លួនច្រើនពេកនៅលើអ៊ីនធឺណិត ពីព្រោះគេអាចយកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកទៅប្រើប្រាស់ដើម្បីធ្វើបាបអ្នកបាន។

• មិនត្រូវផ្សព្វផ្សាយអ្វីដែលបន្ទាប ឬបង្ខូចតម្លៃវប្បធម៌ ឬសេចក្តីថ្លៃថ្នូររបស់ជាតិអ្នក និងជាតិដទៃ។

• មិនត្រូវផ្សព្វផ្សាយអ្វីដែលប៉ះពាល់ដល់សន្តិសុខរបស់ជាតិដូចជាព័ត៌មានសម្ងាត់ទាក់ទងនឹងកងទ័ពការពារទឹកដី ព័ត៌មានស៊ើបអង្កេតរបស់សមត្ថកិច្ចក្នុងការទប់ស្កាត់ចរាចរណ៍គ្រឿងញៀនជាដើម។

• មិនត្រូវផ្ញើ ឬ ផ្សព្វផ្សាយបន្តព័ត៌មាន សេចក្តីប្រកាស រូបភាព ឬវីដេអូណាមួយដោយសារតែពាក្យគំរាមថាអ្នកនឹងជួបរឿងអពមង្គលប្រសិនបើមិនផ្សព្វផ្សាយវាបន្ត ឬសារជំរុញថាអ្នកនឹងជួបរឿងមង្គលប្រសិនបើអ្នកផ្ញើវាទៅកាន់មិត្តភក្តិឬផ្សព្វផ្សាយបន្តទៀត។

• មិនត្រូវជឿទាំងស្រុងនូវអ្វីៗដែលអ្នកបានឃើញ ឬបានឮនៅលើអ៊ីនធឺណិតព្រោះអ្វីៗនៅលើអ៊ីនធឺណិតមិនប្រាកដថាពិតនិងត្រឹមត្រូវទាំងអស់ឡើយ។

## គោលការណ៍ទី ៤

# ការគោរពនិងការពារទ្រព្យសម្បត្តិ

### គួរធ្វើ

• ត្រូវមានវិធី ឬបច្ចេកទេសក្នុងការថែរក្សារូបថត វីដេអូអត្ថបទ សំឡេង រូបភាព... របស់ខ្លួននៅលើអ៊ីនធឺណិតឱ្យមានសុវត្ថិភាព។ ដើម្បីការពារទ្រព្យសម្បត្តិរបស់អ្នកដែលនៅលើអ៊ីនធឺណិត អ្នកត្រូវយល់ដឹងពីច្បាប់កម្មសិទ្ធិបញ្ញា និងភ្ជាប់ព័ត៌មានទាក់ទងនឹងការរក្សាកម្មសិទ្ធិបញ្ញាចំពោះអ្វីៗដែលអ្នកដាក់ផ្សាយលើបណ្តាញអ៊ីនធឺណិតជាដើម។

• ត្រូវគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ម្ចាស់រូបថត វីដេអូ អត្ថបទ ឬខ្សែអាត់សំឡេងដែលអ្នកផ្សព្វផ្សាយនៅលើអ៊ីនធឺណិត។

• ត្រូវគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់បុគ្គលនៅក្នុងរូបថត វីដេអូ ឬសារសំឡេងដែលត្រូវបានផ្សព្វផ្សាយនៅលើអ៊ីនធឺណិត។

• ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ប្រសិនបើអ្នកធ្វើការទូទាត់ប្រាក់តាមអ៊ីនធឺណិត។ អ្នកត្រូវតែធ្វើឱ្យប្រាកដថាបុគ្គលដែលអ្នកបង់ប្រាក់ឱ្យមិនមែនជាមនុស្សបោកប្រាស់ ហើយមធ្យោបាយទូរទាត់ប្រាក់មាន

សុវត្ថិភាពខ្ពស់។

**មិនត្រូវធ្វើ**

• មិនត្រូវលួចព័ត៌មាន ឬស្នាដៃអ្នកដទៃមកធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួន។

• មិនត្រូវទាញយក (Download) ឬដាក់ផ្សាយវីដេអូ បទចម្រៀងរូបភាព ឬឯកសារដែលត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញា ក្នុងគោលបំណងយកទៅធ្វើអាជីវកម្មសម្រាប់ប្រាក់ចំណេញផ្ទាល់ខ្លួនឡើយ។

• មិនត្រូវលួចគណនីឬលេខសម្ងាត់របស់អ្នកដទៃ។

• មិនត្រូវផ្សព្វផ្សាយនិងរកស៊ីបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត។

• មិនត្រូវទិញដូរ ឬបង់ប្រាក់តាមអ៊ីនធឺណិតដោយមិនបានត្រួតពិនិត្យផលិតផលជាមុន និងមានប្រព័ន្ធធានារ៉ាប់រងការទូរទាត់ប្រាក់ត្រឹមត្រូវ។

# គោលការណ៍ទី ៥

# ការគោរពជីវភាពឯកជន

## ត្រូវធ្វើ

• ត្រូវគោរពឯកជនភាព[5]របស់អ្នកនិងអ្នកដទៃ។

• ត្រូវការពារព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកឱ្យបានល្អបំផុតលើប្រព័ន្ធអ៊ីនធឺណិត។

• ត្រូវរាយការណ៍ (report) អ្នកប្រើប្រាស់អ៊ីនធឺណិត ឬប្រព័ន្ធផ្សព្វផ្សាយសង្គមណាដែលរំលោភជីវភាពឯកជនរបស់អ្នក ឬអ្នកដទៃ។

• ត្រូវរាំងខ្ទប់ (block) និងរាយការណ៍ (report) អ្នកប្រើប្រាស់អ៊ីនធឺណិតឬប្រព័ន្ធផ្សព្វផ្សាយសង្គមណាដែលរំលោភឯកជនភាពរបស់អ្នកដទៃប្រើប្រាស់ពាក្យពេចន៍អសុរស ផ្សព្វផ្សាយព័ត៌មានមិនពិតនិងរូបភាព ឬវីដេអូអាសអាភាសជាដើម។

---

[5] *ជីវភាពឯកជន = privacy*

## មិនត្រូវធ្វើ

• មិនត្រូវបង្ហាញឬផ្សព្វផ្សាយព័ត៌មានសម្ងាត់របស់ខ្លួននៅលើអ៊ីនធឺណិត និងមិនត្រូវលួចព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកដទៃតាមអ៊ីនធឺណិត។

• មិនត្រូវផ្សព្វផ្សាយ ឬចែករំលែករូបថត វីដេអូ អត្ថបទ ឬសារជាសំឡេងរបស់អ្នកដទៃដោយគ្មានការអនុញ្ញាត៕

